ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

នាយដ្ឋានផ្សព្វផ្សាយកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម

# បច្ចេកទេសដាំដំណាំស្វាយ ចន្ទី









**សហការផលិតដោយ:**

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម និងនាយកដ្ឋានដំណាំឧស្សាហកម្ម

ឧបត្ថម្ភ ការបោះពុម្ពផ្សាយដោយ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ឆ្នាំ២០១៦

# សៀវភៅ

## ស្ដីពី

# ដំណាំស្វាយចន្ទី

សហការរៀបចំដោយ

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម និងនាយកដ្ឋានដំណាំឧស្សាហកម្ម

នៃអគ្គនាយកដ្ឋានកសិកម្ម

បោះពុម្ពលើកទី១ ចំនួន ២០០០ ច្បាប់

ផលិតដោយ: នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយ: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

រក្សាសិទ្ធដោយ: នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

# សមាសភាពចូលរួមចំណែកផលិតសៀវភៅ
# ស្ដីពីដំណាំស្វាយចន្ទី

I. ទីប្រឹក្សាផ្ដល់យោបល់:

| | | |
|---|---|---|
| ១. បណ្ឌិត | **ម៉ាក់ សឿន** | អគ្គនាយកដ្ឋានកសិកម្ម |
| ២. បណ្ឌិត | **ម៉ៅ មីនា** | នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម |
| ៣. លោក | **ខាន់ សំបាន** | នាយកដ្ឋានដំណាំឧស្សាហកម្ម |
| ៤. លោក | **ប៉ែន វុទ្ធី** | នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម |
| ៥. លោក | **គឹម ដារ៉ា** | នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម |

II. អ្នករៀបរៀង:

| | | |
|---|---|---|
| ១. លោក | **ផាន ទូច** | នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម |

III. ក្រុមអ្នកស្រាវជ្រាវ:

| | | |
|---|---|---|
| ១. លោក | **ឃួន អៀខ** | សាកលវិទ្យាល័យភូមិន្ទកសិកម្ម |
| ២. លោក | **ស៊ីប បញ្ញាសុឡី** | សាកលវិទ្យាល័យភូមិន្ទកសិកម្ម |

IV. ក្រុមការងារត្រួតពិនិត្យ និងកែសម្រួល:

| | | |
|---|---|---|
| ១. លោក | **យិន ច័ន្ទសុធី** | នាយកដ្ឋានដំណាំឧស្សាហកម្ម |
| ២. លោក | **ហែម សុភីន** | នាយកដ្ឋានដំណាំឧស្សាហកម្ម |
| ៣. លោក | **ពេជ សុខន្តារ៉ា** | នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម |
| ៤. លោក | **ហុខ ទ្រី** | នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម |



## មាតិកា ទំព័រ


១. សេចក្តីផ្តើម ............................................................ ១

២. ស្ថានភាពដំណាំស្វាយចន្ទីនៅកម្ពុជា.......................................... ១

៣. លក្ខណៈរូបសាស្ត្ររបស់ដំណាំស្វាយចន្ទី..................................... ១

៣.១ លក្ខណៈរបស់ដើម.............................................................. ១

៣.២ លក្ខណៈរបសឫស................................................................ ២

៣.៣ លក្ខណៈរបស់ស្លឹក............................................................... ២

៣.៤ លក្ខណៈរបស់ផ្កា.................................................................. ៣

៣.៥ លក្ខណៈរបស់គ្រាប់.............................................................. ៣

៤. លក្ខណៈបរិស្ថានសម្រាប់ដំណាំស្វាយចន្ទី.................................... ៤

៤.១ សីតុណ្ហភាព...................................................................... ៤

៤.២ ទឹកភ្លៀង............................................................................ ៤

៤.៣ សំណើមបរិយាកាស............................................................. ៤

៤.៤ ខ្យល់................................................................................ ៤

៤.៥ ពន្លឺ................................................................................. ៥

៤.៦ ដី.................................................................................... ៥



ម.ព.ឯ.ក AIDOC
Code:
Date:
Donated by:

៥. ប្រភេទពូជមួយចំនួនដែលមាននៅប្រទេសកម្ពុជា.......................៥
៦. ការជ្រើសរើសពូជស្វាយចន្ទី.......................................................៥
៧. ការពង្រីកពូជ..........................................................................៦
៧.១ ការបណ្តុះគ្រាប់.......................................................................៦
៧.២ ការបំបៅកូនស្វាយចន្ទី ឬតត្រួយ..............................................៧
៨. បច្ចេកទេសដាំដុះស្វាយចន្ទី.....................................................៩
៨.១ ការរៀបចំចម្ការដាំស្វាយចន្ទី.................................................៩
៨.២ ការរៀបចំដី..........................................................................១១
៨.៣ ការរៀបចំរណ្តៅ.....................................................................១១
៨.៤ ការដាំដុះ.............................................................................១២
៩. ការថែទាំទូទៅក្នុងចម្ការចាស់.................................................១៦
៩.១ ការបោះបង្គោលជាប់កូនឈើ និងគម្របដី.................................១៦
៩.២ ការកាត់តែងមែក....................................................................១៧
៩.៣ ការស្រោចស្រព.......................................................................១៨
៩.៤ ការអភិរក្សដី និងទឹក...............................................................១៩
៩.៥ ការប្រើប្រាស់ជី.......................................................................២០
១០. ការគ្រប់គ្រងជំងឺ និងសត្វល្អិតចង្រៃ........................................២២
១០.១ ជំងឺ.....................................................................................២២
១០.២ សត្វល្អិតលើដំណាំស្វាយចន្ទី...............................................២៦
១១. ការប្រមូលផល ......................................................................៣០

# ដំណាំស្វាយចន្ទី



## ១. សេចក្តីផ្តើម

ស្វាយចន្ទីជាប្រភេទដំណាំយកផ្លែ និងគ្រាប់។ ដំណាំនេះ មិនមែនមានតែក្នុងប្រទេសកម្ពុជាយើងទេ គឺមាននៅប្រទេសតំបន់តូពិចជាច្រើនបានដាំដំណាំនេះ ហើយគេបានធ្វើការអភិវឌ្ឍដំណាំនេះផងដែរ ព្រោះបច្ចុប្បន្នសេចក្តីត្រូវការលើផលិតផលនៃដំណាំស្វាយចន្ទីកំពុងតែកើនឡើងជាលំដាប់។ ហេតុដូច្នេះហើយ បានជាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានផែនការជំរុញឱ្យកសិករខិតខំដាំដុះដំណាំនេះ ឱ្យបានច្រើនជាអតិបរិមា ដើម្បីបម្រើសេចក្តីត្រូវការហូបចុកនៅក្នុងប្រទេស និងធ្វើការនាំចេញទៅក្រៅប្រទេសថែមទៀត ស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល។

## ២. ស្ថានភាពដំណាំស្វាយចន្ទីនៅកម្ពុជា

ដំណាំស្វាយចន្ទី ជាប្រភេទដំណាំដែលគេដាំតាមតំបន់ខ្ពង់រាប និងវាលទំនាបដែលពុំលិចទឹកស្ទើរគ្រប់ខេត្តក្រុងក្នុងប្រទេសកម្ពុជា ដែលមានផ្ទៃដីដាំដុះចំនួន ៦៦.៥១៣ ហ.ត (ស្ថិតិកសិកម្ម ឆ្នាំ២០០៩)។

## ៣. លក្ខណៈរូបសាស្ត្ររបស់ដំណាំស្វាយចន្ទី

### ៣.១ ដើម

ដើមស្វាយចន្ទីមានសាច់ឈើរឹងមធ្យម និងមានសំបកពណ៌ត្នោតប្រផេះ

មានកម្ពស់ពី ៦-១២ម និងមានអង្កត់ផ្ចិតពី ៣០,៤៦-៩១,៤៩ស.ម។ ដើមស្វាយចន្ទីបែកមែកសាខា ដែលអង្កត់ផ្ចិត នៃការបែកមែកមានពី ៤-១២ម មានបែកខ្នែងជាច្រើន និងមានមែកតូចៗជាច្រើនទៀតដុះចេញពីមែកជាប់ដើម។



## ៣.២ ឫស

ឫសស្វាយចន្ទីអាចចាក់ចូលទៅក្នុងដីបានជម្រៅ ៣-៤ម។ ឫសចំហៀងរបស់ស្វាយចន្ទីដុះលូតលាស់ទៅតាមអាយុរបស់វា គឺនៅអាយុ ១,៥ឆ្នាំ បែកបាន ១,២មនៅអាយុ ២.៥ ឆ្នាំ បែកបាន ៤,៦ម នៅអាយុ ៣,៥ឆ្នាំ បែកបាន៥,៦ម និងនៅអាយុ ៦ឆ្នាំ បែកបាន ៧,៣ម។



## ៣.៣ ស្លឹក

ស្លឹកស្វាយចន្ទីជាប្រភេទស្លឹកឆ្លាស់គ្នា មានពណ៌បៃតងរាងទ្រវែង និងរមូរខាងចុងដូចស្លឹកប៉ោម ដែលមានបណ្តោយពី ១០-



១២ស.ម និងទទឹង ៥-៥,៧ស.ម ហើយមានទ្រនុងអណ្តែតចេញពីផ្ទៃស្លឹក មានក្លិនប្រហើរ មានឆ្នូត ពណ៌ស៊ីជម្ពូ ឬក្រហមចាស់អាស្រ័យទៅតាមពូជ។

## ៣.៤ ផ្កា



កញ្ចុំផ្កា ស្វាយចន្ទីមានលក្ខណៈ ជាចង្កោមមានទ្រង់ទ្រាយប្រហែលផ្កាស្វាយដែរ ។ ដំណាំស្វាយចន្ទីចេញផ្កាចាប់ពីអាយុ ២ ឆ្នាំ ផ្កាវា ចេញនៅតាមចុងមែក។ ផ្កាមានលក្ខណៈជាចង្កោម ដែលក្នុងមួយចង្កោមៗ មានផ្កាឈ្មោល និងផ្កាទ្វេភេទ។ នៅក្នុងមួយចង្កោមផ្កាមានផ្កាឈ្មោលប្រមាណ ៧៥,១ភាគរយ និងផ្កាទ្វេភេទ ២៤,៩%។

## ៣.៥ គ្រាប់

គ្រាប់ស្វាយចន្ទី ឋិតនៅខាងក្រៅផ្លែ។ លក្ខណៈរបស់គ្រាប់មានរូបរាងដូចជាគ្រាប់សណ្តែក ឬរាងដូចតម្រងនោម បែងចែកកូទីលេដុង ជាពីរស្មើគ្នា។ ពេលក្តិប មានពណ៌ស៊ីជម្ពូ បន្ទាប់មកមានពណ៌បៃតងនៅពេល លូតលាស់ធំធាត់ដល់កំរិត វាប្រែជាពណ៌ប្រផេះ និងពណ៌ត្នោតចាស់។



## ៤. លក្ខណៈជីវសាស្ត្ររបស់ដំណាំស្វាយចន្ទី

### ៤.១ សីតុណ្ហភាព

ស្វាយចន្ទីត្រូវការសីតុណ្ហភាពថេរ គឺមិនត្រជាក់ពេក មិនក្តៅពេក។ សីតុណ្ហភាពខ្ពស់បំផុត ៣៤អង្សាសេ និងសីតុណ្ហភាពទាបបំផុត ១៨អង្សាសេ ប៉ុន្តែសីតុណ្ហភាពល្អបំផុតចន្លោះពី ២៤-២៨អង្សាសេ។ ប្រសិនបើសីតុណ្ហភាពមិនខ្ពស់ជាង ២០អង្សាសេទេ ស្វាយចន្ទីពិបាកលូតលាស់ណាស់ ហេតុដូច្នេះសីតុណ្ហភាពល្អបំផុតប្រចាំខែគឺ ២៧ អង្សាសេ។

### ៤.២ ទឹកភ្លៀង

ការដាំដុះស្វាយចន្ទីទទួលបានជោគជ័យអាស្រ័យលើការទទួលបានទឹកភ្លៀង៥ខែ និងលទ្ធភាពនៃការស្រូបទឹកទុករបស់ដីបានល្អ។ ស្វាយចន្ទីអាចដាំបាននៅតំបន់ដែលមានភ្លៀងធ្លាក់ពី ៥០០-៤.០០០ម.ម ក្នុងមួយឆ្នាំ។ តំបន់ដែលមានភ្លៀងធ្លាក់តិចជាង ៥០០ម.ម និង តំបន់ដែលមានទឹកភ្លៀងច្រើនជាង ៣.០០០-៤.០០០ម.ម ពេញមួយឆ្នាំ មិនអាចដាំស្វាយចន្ទីបានទេ។ ស្វាយចន្ទីមិនសូវត្រូវការទឹក ៤-៥ខែ គឺនៅដំណាក់កាលចេញត្រួយ និងចេញផ្លែ។

### ៤.៣ សំណើមបរិយាកាស

ស្វាយចន្ទីធន់ទ្រាំនឹងតំបន់ដែលមានសំណើមបរិយាកាសទាប ហើយមានរយៈពេលវែង ផងដែរ។ បើមានសំណើមខ្ពស់ជាង ៨០ភាគរយ ក្នុងកំឡុងពេលចេញផ្កា និងចាប់ផ្តើមចេញផ្លែ គឺជះឥទ្ធិពលមិនល្អដល់បរិមាណ និង គុណភាពទិន្នផលស្វាយចន្ទី។

### ៤.៤ ខ្យល់

ខ្យល់ខ្លាំងធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់ផ្កា និងផ្លែ តែខ្យល់ក៏ជាអ្នកដើរតួក្នុងការនាំលំអងផ្កាផងដែរ។ ដូចនេះខ្យល់ដែលល្អបំផុតដល់ស្វាយចន្ទីគឺពី ២-៧ម៉ែត្រក្នុងមួយវិនាទី ឬ២០គីឡូម៉ែត្រក្នុងមួយម៉ោង។

### ៤.៥ ពន្លឺ

ដំណាំស្វាយចន្ទីជាដំណាំត្រូវការពន្លឺព្រះអាទិត្យ និងមិនត្រូវការម្លប់ច្រើនទេ។ តម្រូវការពន្លឺទាបបំផុតពី ២.០០០-២.៤០០ម៉ោងក្នុងមួយឆ្នាំ តែក្នុងដំណាក់កាលចេញផ្កា និងផ្លែស្វាយចន្ទីត្រូវការពន្លឺ ១.២៨៥ម៉ោង (ខែវិច្ឆិកា-មីនា)។

### ៤.៦ ដី

ស្វាយចន្ទី ជាប្រភេទរុក្ខជាតិមួយធន់ទ្រាំល្អចំពោះដីច្រើនប្រភេទ គឺអាចដាំលើដីគ្រប់ចំណាត់ថ្នាក់ លើកលែង តែដីដែលមានល្បាយឥដ្ឋច្រើនដែលជាដីជាំទឹក ហើយដែលល្អនោះជាដីល្បាយខ្សាច់ មិនដក់ទឹក ស្រស់ទឹកល្អ។ ចំពោះដីបាសាល់ ឬដីក្រហមឡាតារីត គឺជាប្រភេទដីដែលល្អបំផុត ផ្តល់បានផលខ្ពស់ និងផលិតផលមានគុណភាព។ ស្វាយចន្ទី អាចដាំនៅលើដីដែលមានរយៈកម្ពស់ ៧០០ម ពីកម្ពស់ទឹកសមុទ្រ។

## ៥. ប្រភេទពូជមួយចំនួនដែលមាននៅប្រទេសកម្ពុជា

សព្វថ្ងៃនេះ មានពូជស្វាយចន្ទីជាច្រើនបានដាំដុះនៅក្នុងប្រទេសកម្ពុជា ទាំងពូជក្នុងស្រុក និងពូជនាំចូលពីក្រៅ។ តែសព្វថ្ងៃនេះ មានពូជ M-23 M-7 S-40 ជាពូជថ្មីដែលកសិករចូលចិត្តដាំជាងគេ ព្រោះវាជាពូជធន់ទ្រាំនឹងជំងឺសត្វល្អិត និងលូតលាស់លឿន បែកមែកសាខា ហើយគ្រាប់មានទំហំធំ។

## ៦. ការជ្រើសរើសពូជស្វាយចន្ទី

ដើម្បីទទួលបានទិន្នផលខ្ពស់ គេគួរតែអនុវត្តវិធីសាស្រ្តពង្រីកពូជតាមការអនុវត្តការផ្សាំ ឬបំបៅ(តត្រួយ)។ ខាងក្រោមនេះ ជាវិធីសាស្រ្តមួយចំនួនដើម្បីជ្រើសរើសពូជស្វាយចន្ទី ឱ្យទទួលបានទិន្នផលខ្ពស់:

- រើសស្វាយចន្ទី ដែលដុះលូតលាស់លឿន ហើយបែកមែកសាខា
- ត្រូវមានពី ១០-៣០ ចង្កោមផ្កាក្នុងមួយម៉ែត្រការ៉េ និង បើសិនមាន

ច្រើនជាងនេះកាន់តែប្រសើរ

- ត្រូវមានផ្កាឈ្មោលពី ២០០-៣០០ផ្កា និងមានផ្កាទ្វេភេទពី ៤០-៨០ ក្នុងចង្កោមផ្កានោះ ហើយបើមានផ្កាទ្វេភេទច្រើនជាងនេះ វាអាចមានសក្តានុពលផ្តល់ផលកាន់តែខ្ពស់
- គ្រាប់ត្រូវមានទម្ងន់ជាមធ្យមពី ៧-៩ក្រាមក្នុងមួយគ្រាប់ ឬ ១២០-១៥០គ្រាប់ក្នុងមួយគីឡូក្រាម
- ដើមស្វាយចន្ទីពូជត្រូវចេញផ្កានៅពាក់កណ្តាលរដូវ (ខែមករា-កុម្ភៈ) ឬនៅចុងរដូវ (ខែកុម្ភៈ-មីនា) ដើម្បីចៀសវាងពីការបំផ្លាញរបស់មូសតែ ហើយត្រូវចេញផ្ការយៈពេលខ្លី (១-៣ខែ)
- ដើមពូជត្រូវធន់ទ្រាំនឹងសត្វល្អិត ជំងឺ និងអាកាសធាតុក្នុងតំបន់
- គ្រាប់ដែលប្រមូលផលពីដើមពូជ ត្រូវតែបានសាច់លើសពី ២៨%
- ពេលដើមមេពេញវ័យ(១៥ឆ្នាំឡើងទៅ) ត្រូវបានគ្រាប់ពី ១៥-២៥ គីឡូក្រាមក្នុងមួយឆ្នាំ
- នៅដំណាក់កាលដំបូង ដើមពូជដែលមានអាយុ ៨ឆ្នាំ ត្រូវប្រមូលផលបានលើសពី ១០គីឡូក្រាម ក្នុង មួយឆ្នាំ

## ៧. ការពង្រីកពូជ

### ៧.១ ការបណ្តុះគ្រាប់

- គ្រាប់ដែលយកមកបណ្តុះ ត្រូវយកគ្រាប់ដែលប្រមូលផលនៅរដូវថ្មីៗពីដើមដែលធន់ទ្រាំ ហើយមានទិន្នផលខ្ពស់ នៅពេលប្រមូលផលច្រើនបំផុត (ខែកុម្ភៈ-មេសា) ព្រោះធ្វើឱ្យដំណុះបានល្អ។
- យកគ្រាប់ដែលជ្រើសរើសបានត្រាំទឹកត្រជាក់ធម្មតា រយៈពេល ២៤ ម៉ោង ដើម្បីឱ្យឆាប់ដុះ និងយកតែគ្រាប់ដែលលិចក្នុងទឹកមកបណ្តុះ ។

◔ យកគ្រាប់ដែលត្រាំទឹករួច ទៅកប់ក្នុងដីមានច្រកថង់រួច ជម្រៅ ២,៥ ស.ម ដែលល្បាយដីក្នុងថង់មានអត្រា (១:១:១) នៃដីធម្មតា ផេះអង្កាម និង ដីកំប៉ុស្ដ ហើយបន្ថែមកំបោរថ្ម ៥ក្រាមក្នុងល្បាយនោះ។

◔ ស្រោចទឹក ជាប្រចាំ គ្រាប់ស្វាយចន្ទីនឹងដុះឡើង ក្នុងរយៈពេល ១៥-២០ថ្ងៃ បន្ទាប់ពីដាក់គ្រាប់ក្នុងដី



ថ្នាលបណ្ដុះកូនស្វាយចន្ទី

◔ កូនស្វាយចន្ទីអាចយកដាំបាន ក្នុងរយៈពេល៣ខែ តែបើយកទៅបំបៅគឺ នៅអាយុ ៣០-៤០ថ្ងៃ បន្ទាប់ពីដុះ។



កូនស្វាយចន្ទីទើបដុះ



កូនស្វាយចន្ទីដុះពេញលេញ

## ៧.២ ការបំបៅកូនស្វាយចន្ទី ឬតត្រួយ

មានវិធីជាច្រើនក្នុងការបំបៅ ឬតត្រួយស្វាយចន្ទី ហើយវិធីនីមួយៗអាចមានប្រសិទ្ធភាពអាស្រ័យលើ ការស្ទាត់ជំនាញ និងការហ្វឹកហាត់របស់អ្នកអនុវត្ត។ ក្នុងនេះ យើងសូមលើកយកវិធីសាស្ត្រមួយ ដែលមានប្រសិទ្ធភាពខ្ពស់

និងងាយស្រួលអនុវត្តក្នុងការបំបៅ ឬតត្រួយស្វាយចន្ទី ហើយជាវិធីដែលកសិករខ្មែរបានអនុវត្តភាគច្រើននៅខេត្តកំពង់ចាម និងកំពង់ធំ គឺវិធីតត្រួយ ឬបំបៅតាមការស៊កត្រួយតភ្ជាប់។

ត្រួយដែលជ្រើសរើសសម្រាប់យកមកបំបៅ ត្រូវតែមានអាយុយ៉ាងហោចណាស់ ២ខែ មានពណ៌បៃតង គ្មានការបំផ្លាញពីសត្វល្អិត និងជំងឺ ហើយត្រូវកាត់ស្លឹកចេញពីត្រួយ ដែលបានជ្រើសរើសនៅលើដើម ពី ១-២សប្តាហ៍ មុនយកមកបំបៅ។

កូនទម្រសម្រាប់យកមកបំបៅ ក៏ត្រូវជ្រើសរើសយកកូនស្វាយចន្ទី ដែលបណ្តុះរួចនោះ មានអាយុ ២ខែ ហើយមានសុខភាពល្អ រឹងមាំ និងគ្មានការបំផ្លាញពីសត្វល្អិត និងជំងឺ។

ការបំបៅ ឬតត្រួយកូនស្វាយចន្ទី ត្រូវអនុវត្តតាមវិធី ដូចខាងក្រោម៖

- យកកូនទម្រ ត្រូវកាត់ស្លឹកចេញឱ្យអស់ទុកតែ ២គូ ក្រោមគេបំផុត
- កាត់ចុងកូនទម្រ ទុកប្រវែង ១៥ស.ម ពីដី រួចយកកាំបិតមុតពុះចំកណ្តាលដើមដែលកាត់រួច ជម្រៅប្រមាណ ៣-៥ស.ម
- កាត់ត្រួយពីដើមមេពូជប្រវែងប្រមាណ ១០-១៥ស.ម រួចយកមកចិតជារាងអក្សរវេ (v) ប្រវែងប្រមាណ ៣-៥ស.ម ដោយលៃយ៉ាងណាឱ្យសំបកនៅជាប់ទាំងសងខាង និងមុខចិតត្រូវតែរាបស្មើ។
- យកត្រួយដែលចិតរួច ស៊កចូលទៅក្នុងកូនទម្រដែលពុះរួចនោះ ឱ្យលឿនតាមអាចធ្វើទៅបាន និងលៃយ៉ាងណា ឱ្យសម្បកម្ខាងនៃត្រួយស្វាយចន្ទីស្មើគ្នានឹងសម្បកកូនទម្រ ដើម្បីឱ្យស្រទាប់សម្បកត្រួតស៊ីគ្នា។
- យកថង់ប្លាស្ទិក (ប្លាស្ទិកស្តើងសម្រាប់រុំពេលបំបៅកូនឈើ) រុំចងកន្លែង

មុខតឱ្យតឹង រួចរុំគ្របដល់ចុងត្រួយ ការពារការចូលទឹក និងការបំភាយចំហាយទឹក។

- ការបំបៅត្រូវធ្វើឡើងនៅកន្លែងថ្នាលបណ្តុះ និង មានម្លប់សមស្រប ចំពោះកូនដែលបំបៅរួច ត្រូវដាក់នៅកន្លែងម្លប់រយៈពេល ១៥ថ្ងៃ។

- កូនបំបៅរួចនេះ ត្រូវទុក នៅកន្លែងបណ្តុះ ដល់រដូវដាំ លើកក្រោយ ហើយពេលនេះ បើមានពន្លកដុះចេញ ពីកូនទម្រ ត្រូវកាត់វាចេញ។



ការបំបៅកូនស្វាយចន្ទី

- ថង់ប្លាស្ទិកដែលរុំ ត្រូវកាត់វាចេញនៅពេលបំបៅរួចបាន ៣-៤ខែនិងអាចយកទៅដាំបាននៅពេលបន្ទាប់។





កូនស្វាយចន្ទីបំបៅរួច

## ៨. បច្ចេកទេសដាំដុះដំណាំស្វាយចន្ទី

### ៨.១. ការរៀបចំចម្ការដាំស្វាយចន្ទី

ចំពោះដំណាំស្វាយចន្ទី ដែលជាដំណាំឧស្សាហកម្មមានរយៈពេលយូរមកហើយការដាំលើផ្ទៃដីធំទូលាយ ដូច្នេះទាមទារនូវការរៀបចំដីតាមលក្ខណៈបច្ចេកទេសឱ្យបានម៉ត់ចត់ ទើបគេអាចទទួលបានលទ្ធផលច្រើន។

**វិធីសាស្ត្រក្នុងការរៀបចំដីរួមមាន ៖**

- ការកាប់ឆ្ការព្រៃ
- ការសាងសង់ផ្លូវ
- ការសាងសង់ប្រឡាយទឹក
- ការដាំដំណាំគម្របដី
- ការកាប់ឆ្ការព្រៃ

ចំពោះបញ្ហាកំលាំងពលកម្ម គេអាចប្រើប្រាស់កម្មករ និងគ្រឿងយន្តដើម្បីសំអាត និង រៀបចំដី។ ចំពោះដើមឈើងាប់ គេត្រូវគរវាជាគំនររួចធ្វើការដុតដោយប្រុងប្រយ័ត្ន។ ចំពោះគល់ឈើត្រូវឱ្យកម្មករកាប់ ឬគាស់ ឬដោយម៉ាស៊ីន។ ម៉្យាងទៀតឫស និង គល់ឈើត្រូវយកវាឱ្យអស់ពីដីរួចគរជាគំនរហាលឱ្យស្ងួត រួចដុតវាចោល ។ ចំពោះករណីដុតព្រៃជាទ្រង់ទ្រាយធំ ជាធម្មតាប្រព្រឹត្តទៅ ៦-៨ សប្តាហ៍ក្រោយពេលកាប់ឆ្ការ ។ ការសង់ផ្លូវបន្ទាប់ពីដុតព្រៃរួច ការសង់ផ្លូវត្រូវគិតគូរជាបន្ទាន់ ដោយប្រយ័ត្ន និង ដោយធ្វើការកំណត់ឱ្យបានច្បាស់ ។ ផ្លូវត្រូវមានទទឹង ៥-៦ ម ងាយស្រួលដល់ការដឹកផលិតផល។

**ការសង់ប្រឡាយ:**

**លក្ខណៈនៃប្រឡាយ ៖** ផ្នែកបាតខាងលើពី ២-៦ ម ផ្នែកបាតខាងក្រោមពី ១,២-១,៨ ម ជំរៅ ១,៨-២,៧ ម។ ដោយចន្លោះប្រឡាយមួយទៅប្រឡាយមួយមិនលើសពី ១០០ ម ហើយកូនប្រឡាយទាំងនោះត្រូវជីកកែងនិង ប្រឡាយមេ ដែលមានទំហំប្រែប្រួលពី ៖

- ផ្នែកបាតលើពី ១,៨-២,៧ ម
- ផ្លែកបាតក្រោមពី ០,៦-០,៩ ម

ជំរៅមាន ១,២-១,៨ ម ដើម្បីងាយស្រួលគ្រឿងយន្តដំណើរការកូនប្រឡាយដែលជីកចូលចម្ការត្រូវតែមានលក្ខណៈស្របគ្នាហើយមានទិសដៅតែមួយ ។

## ៨.២ ការរៀបចំដី

ដំណាំស្វាយចន្ទីជាដំណាំត្រូវការពន្លឺ ដូច្នេះដីដែលត្រូវដាំដំណាំនេះ មិនត្រូវឱ្យមានដំណាំណា ដុះគ្របពីលើ ឬមានម្លប់បាំងពីលើទេ។ ចំពោះឫសឈើដែលនៅក្នុងដី ត្រូវសំអាតចេញពីកន្លែងដាំយ៉ាងហោចណាស់ ២ម បួនជ្រុង និងគួរដាំដំណាំគម្របដី ដើម្បីការពារសំណើមដី និងអាចជួយបង្កើនជីជាតិដីបានថែមទៀតផង។

## ៨.៣ ការជីករណ្តៅ

ការជីករណ្តៅ ត្រូវជីក ៥០ស.ម បួនជ្រុង និងជំរៅ ៥០ស.មដែរ។ ការជីកនេះត្រូវបែងចែកដីស្រទាប់លើដាក់ផ្សេង និងដីស្រទាប់ក្រោមដាក់ផ្សេង ដើម្បីយកដីស្រទាប់លើនេះ មកលាយជាមួយជីកំប៉ុស្ត និងកំបោរថ្ម សម្រាប់លុបវិញ ដោយពេលដាំដាក់នៅស្រទាប់ខាងក្រោម។ ហើយការជីកនេះ គួរជីកក្នុងអំឡុងខែមេសា ដើម្បីហាលរណ្តៅ សម្លាប់មេរោគ សម្រាប់ដាំនៅខែឧសភា ឬដើមរដូវវស្សា។

ចំពោះចន្លោះគុម្ពសម្រាប់ដាំស្វាយចន្ទី វាអាស្រ័យទៅតាមប្រភេទដី និងជីជាតិរបស់ដី សមត្ថភាពផ្ទុកទឹក របស់ដី ពូជស្វាយចន្ទីដែលត្រូវដាំ។ ចំពោះពូជ M-23 M-7 S-40 បើដាំនៅតំបន់ដីក្រហមក្នុងខេត្តកំពង់ចាម រតនៈគីរី គេច្រើនដាំចន្លោះគុម្ព ១០x១០ម និង ១២x១២ម។ ចំណែកដីខ្សាច់ ដូចជាខេត្តកំពង់ធំ គេច្រើនដាំចន្លោះគុម្ព ៨x៨ម ៩x៩ម និង១០x១០ម។

ជាទូទៅគួរតែជីករណ្តៅដែលមានទំហំ១ ម x ១ ម x ១ ម ចំពោះដីល្បាយ

ខ្សាច់។ ចន្លោះដើម ៨ ម x ៨ ម ជាការល្អ។ ក្នុងករណីដីជំរាលធ្វើចង្អូរកាត់ដីជំរាល ពី ១០-១៥ ម ។ ប្រសិនបើដីបន្ទាប់ពីស្រទាប់លើរឹងមានរាងដូចខ្ទះ ដូចនេះទំហំរណ្តៅត្រូវបង្កើតឡើងឱ្យធំ១.២ ម x ១,២ ម x ១,២ ម ស្វាយចន្ទីដាំនៅចន្លោះជួរ ៨ ម x ៨ ម ចន្លោះជួរនេះក៏ផ្តល់លទ្ធភាពក្នុងការលូតលាស់ដែរ។រណ្តៅត្រូវជីក១៥-២០ថ្ងៃដំបូងការដាំដុះហើយដាក់ឱ្យត្រូវថ្ងៃដើម្បីកំចាត់កត្តាចង្រៃនៅក្នុងដី។ បន្ទាប់មករណ្តៅត្រូវបំពេញកម្ពស់ ៣/៤ ដោយលាយចម្រុះគ្នាដូចជា ដីស្រទាប់លើ ដីកំប៉ុស្តិ៍ ១១ គ.ក្រ និង ថ្មផូស្វាតធម្មជាតិ ២០០ ក្រាម។ ប្រសិនបើដីរាបស្មើ ការត្រៀមដីស្មើរតែមិនចាំបាច់ធ្វើអ្វីឡើយ គ្រាន់តែសំអាតស្មៅចង្រៃចេញ ឬ ក៏ធ្វើការភ្ជួរពីរដងហើយដាក់ដាំស្វាយចន្ទីឱ្យមានជួរតាមរបៀបរៀបរយ។ ប៉ុន្តែ ដីដែលមានព្រៃត្រូវគាស់រំលើងយកគល់ចេញជាមុនសិន ដើម្បីងាយស្រួលក្នុងការថែរក្សា ប្រសិនបើជាដីទួល គួរពង្រាបទៅតាមជំរាលដី។ ម៉្យាងទៀតបើដីនោះចោតខ្លាំង ឬ ដីភ្នំ ការដាំដុះធ្វើឡើងជាកាំជណ្តើរដើម្បីការពារ ការហូរច្រោះ និងការបាក់ដី។ ការត្រៀមដីគួរធ្វើឱ្យស្រេចនៅក្នុងរដូវក្តៅ ដែលអាចជីករណ្តៅនឹងដាំបាននៅក្នុង រដូវភ្លៀង។

### ៨.៤ ការដាំដុះ

ការដាំដុះស្វាយចន្ទីភាគច្រើនគេដាំនៅរដូវវស្សា ដោយយកតែកូនដែលមានសុខភាពល្អមកដាំ ហែកថង់បណ្តុះចេញ និងធ្វើយ៉ាងណាកុំឱ្យបែកដីក្នុងថង់នោះ រួចដាក់វាថ្នមៗ ចូលក្នុងរណ្តៅដែលបានជីករួច និងយកដីដែលបានលាយជាមួយជីកំប៉ុស្ត លុបបំពេញរណ្តៅនោះ។ ស្រោចទឹកលើកូនស្វាយចន្ទីដែលដាំរួច និងយកសារធាតុសរីរាង្គដូចជាស្លឹកឈើ ស្មៅក្រៀម និងសារធាតុផ្សេងៗ គ្របជុំវិញគល់ដើម្បីរក្សាសំណើមដី។ ហើយកុំភ្លេចបោះបង្គោលចងកូនស្វាយចន្ទី ដើម្បីការពារខ្យល់ និង ជួយកុំឱ្យកូនស្វាយចន្ទីបំបៅ បាក់បាន

ទៀតផង។




ការដាំស្វាយចន្ទី

ក្នុងករណីបំបៅការថៃទាំគួរតែយកចិត្តទុកដាក់មុខតំណបំបៅ គឺតិចបំផុតលើ ៥ ស.ម ពីមាត់រណ្តៅសំអាត និងជួយឱ្យរកឃើញហើយបន្ទាប់មកកាត់ពន្លកដែលនៅគល់ឫសតែនៅក្រោមមុខតំណបំបៅ។ ផ្នែកដែលនៅសល់ នៃរណ្តៅគួរបំពេញបន្តិចម្តងៗ ចាប់ពីបាតរណ្តៅ រយៈពេល ២ ឆ្នាំ។

### ការត្រៀមគ្រាប់ពូជសម្រាប់ដាំ

- ទម្ងន់គ្រាប់មិនស្រាលជាង ៥ ក្រាមក្នុង ១ គ្រាប់
- នៅពេលត្រាំទឹកគ្រាប់វាលិចទៅក្នុងទឹក

### ពេលវេលាដាំដុះ

ទោះបីជាស្វាយចន្ទីវាធន់ និង ភាពរាំងស្ងួតក៏ដោយ ក៏នៅវគ្គដំបូងនៃការលូតលាស់វាត្រូវការទឹក ដើម្បីការលូតលាស់ធំរឹងប៉ឹងដែរ ដូច្នេះត្រូវកំណត់រដូវដាំដុះឱ្យបានល្អ ។ រដូវកាលដែលសមរម្យសម្រាប់ការដាំដុះ គឺដើមខែមិថុនា ដល់ខែកក្កដា វានឹងទទួលបានទឹកភ្លៀងរយៈពេល៣ខែ ម៉្យាងវិញទៀត

គេអាចដាំវាបាននៅក្នុង ខែសីហាដោយពុំសូវធ្វើ ការស្រោចស្រពច្រើន ។

**ការបណ្ដុះកូននៅក្នុងថ្នាលបណ្ដុះ**

យកគ្រាប់ទៅកប់ក្នុងថ្នាល ដែលបានក្រាលដីខ្សាច់ កំរាស់១៥ ស.ម ។ ការដាក់គ្រាប់ត្រូវយក ផ្នែកខាងផតចុះទៅក្រោម ហើយងើយខាងក្បាលគ្រាប់ឡើងបន្តិច រួចរោយខ្សាច់ពីលើគ្រាប់ឱ្យបានកំរាស់ ២,៥០ ស.ម និងស្រោចទឹក ២ ដង ក្នុងមួយថ្ងៃ នៅពេលព្រឹក និង ពេលល្ងាចរយៈពេល ៦ ថ្ងៃ ក្នុងករណីមានភ្លៀងធ្លាក់ មិនចាំបាច់ស្រោចទឹកទេ ។

**ការបណ្ដុះកូននៅក្នុងថង់ប្លាស្ទិក:**



បេះផ្លែដែលល្អគ្មានការបំផ្លាញពីកត្តាចង្រៃ



ប្រឡេះគ្រាប់ពីផ្លែ



យកដីស្រទាប់លើ ឫដីមមោក



យកដីដែលល្អ



យកដីច្រកចូលក្នុងថង់ប្លាស្ទិក



បង្ហាប់វាឱ្យហាប់ល្មម



ថង់ប្លាស្ទិកដែលបានត្រៀមទុក



យកម្រាមដៃកាយប្រហោង ល្មមដាក់គ្រាប់



ដាក់គ្រាប់ស្វាយចន្ទីចូលក្នុង ប្រហោង



កាយដីលប់ពីលើគ្រាប់



ស្រោចទឹកឱ្យខ្វាយដី



ទុកឱ្យដុះលូតលាស់

ការបណ្ដុះកូននៅក្នុងថង់

ត្រៀមគ្រាប់ពូជដែលបានជ្រើសរើសរួចហើយ ទៅបណ្ដុះក្នុងថង់ប្លាស្ទិក ត្រូវធ្វើការត្រាំគ្រាប់រយៈពេល ២៤ ម៉ោង ទៅ ៤៨ ម៉ោង មុនពេលយកទៅបណ្ដុះ។ ថង់ប្លាស្ទិកគួរប្រើថង់ពណ៌ខ្មៅដែលមានទំហំ ១២,៧ ស.ម x ២០,៣ ស.ម ដោយប្រើថង់ជ្រៅកាន់តែល្អ បើថង់រាក់វាធ្វើឱ្យការចាក់ឫសរបស់វាទាល់ដោយធ្វើការចោះរន្ធចំហៀងឱ្យបាន ពី ៤-៨ រន្ធ ដើម្បីបញ្ចេញទឹកពីក្នុងថង់ ។ ការបណ្ដុះធ្វើឡើងដោយការផ្សំដីជាមួយនឹងផេះអង្កាម ជីទ្រាប់បាត ឬ កំប៉ុស្តិ៍នៅក្នុងអត្រា ៣ ៖១:១ ដោយច្របល់បញ្ចូលគ្នាឱ្យសព្វ ហើយ

ច្រកចូលថង់ដែលបានធ្វើការត្រៀមទុក ឱ្យសល់ពីមាត់ថង់ប្រហែល ១-២ ស.ម ។

### វិធីដាំដោយគ្រាប់:

វិធីនេះសមស្របចំពោះការដាំនៅលើផ្ទៃដីធំទូលាយ ករណីនេះមិនធ្វើឱ្យកូន ររអាក់ររួលក្នុងការលូតលាស់ ហើយម៉្យាងទៀតមិនសូវចំណាយពលកម្មក្នុងការដាំដុះ ប៉ុន្តែត្រូវរង់ចាំថែរក្សានិងការដាំជួសចំពោះរណ្តៅណាដែល មិនដុះ ឬកូនមិនរឹងមាំ ។ ដាក់គ្រាប់ ២-៣ ក្នុង១រណ្តៅដាំតែម្តង ការកប់គ្រាប់មិនត្រូវឱ្យជ្រៅលើសពី ៦ ស.ម ទេព្រោះបើជ្រៅវាមិនដុះ ឬបាត់បង់ចោលទទេ ។ បន្ទាប់ពីកប់គ្រាប់រួចរាល់ហើយត្រូវធ្វើការស្រោចទឹកឱ្យបានល្អ ហើយធ្វើការបោចស្មៅ និង យកចំបើងមកគ្រប ដើម្បីការពារសំណើមមិនឱ្យមានការស្រោចទឹកជាញឹកញាប់។

នៅពេលស្លឹកដុះចេញនូវស្លឹកពិតប្រាកដ ឬរឹងប៉ឹងហើយ ត្រូវធ្វើការដកដើមអន់ចេញឱ្យនៅសល់តែមួយដើម។ ការជីករណ្តៅគួរមានទំហំ ៥០ ស.ម x ៥០ ស.ម និង ជំរៅ ៥០ ស.មហើយចម្ងាយដាំគឺ ៦ ម x ៦ មចំពោះពូជ ក្នុងស្រុក ចំពោះពូជនាំចូលពី ៨ ម x ៨ ម រហូតដល់ ១២ ម x ១២ ម។

## ៩. ការថែទាំទូទៅលើដីចម្ការចាស់

កំឡុង ២-៣ ឆ្នាំម្តង សួនចាស់នៃដំណាំស្វាយចន្ទី មានម្លប់ដោយខ្លួនឯងហើយត្រូវធ្វើការតាក់តែងមែក ដើម្បីសម្រួលដល់ខ្យល់ និង ពន្លឺចាំងចូលគ្រប់គ្រាន់ដើម្បីសម្ងួតដីល្អ ។ ការតាក់តែងមែកត្រូវធ្វើឡើងនៅក្នុងខែ សីហា និងការកាត់ចុងក្រោយ ត្រូវលាប Bordeaux 10% ។

### ៩.១ ការបោះបង្គោលជាប់កូនឈើ និងគម្របដី

បន្ទាប់ពីការដាំកូនបំបៅ ត្រូវយកបង្គោលទៅចងភ្ជាប់។ធ្វើដូចនេះដើម្បី

បង្កាការខូចខាត ដល់កូនបំបៅ ដោយសារខ្យល់ ចំពោះដី ដែលនៅជុំវិញរុក្ខជាតិ ត្រូវគ្រប និងស្លឹកស្ងួត ឬ ស្លឹកស្រស់សម្រាប់ការពារសំណើម កុំឱ្យបាត់បង់។



## ៩.២ ការកាត់មែកស្វាយចន្ទី

ការតាក់តែងមែក ត្រូវធ្វើឡើងចាប់តាំងពីដំណាំនៅតូចទៅ ជារៀងរាល់ឆ្នាំ។ ដំបូងបន្ទាប់ពីដំណាំដាំរួច ពេលឃើញមានមែកដុះចេញពីក្រោមមុខដំណបំបៅ ត្រូវកាត់ចេញ ពោលគឺទុកឱ្យវាបែកមែកចាប់ពីកម្ពស់ ៥០-៧៥ស.ម ឡើងទើបឱ្យបែកមែក ដើម្បីឱ្យដើមមានលទ្ធភាពទប់ទល់ជាមួយខ្យល់បាន ងាយស្រួលប្រមូលផល និងងាយស្រួល ក្នុងការចូលពិនិត្យសត្វបំផ្លាញដើមស្វាយចន្ទី។ ការតាក់តែងមែក គឺត្រូវកាត់មែកដែលខ្សោយ មែកមានជំងឺ មែកដែលនៅក្នុងម្លប់គ្មានបានការចេញ។ ការធ្វើបែបនេះ នឹងជួយឱ្យដើមស្វាយចន្ទីទទួល





ចម្ការស្វាយចន្ទីក្រោយការកាត់តែងមែករួច

បានពន្លឺគ្រប់គ្រាន់ លូតលាស់បានល្អ កាត់បន្ថយការបំផ្លាញពីសត្វល្អិត។

ដើមដាំដោយគ្រាប់ និងដើមបំបៅដោយត្រួយក្រោយពេលដាំបានអាយុ ១-៣ ឆ្នាំ ត្រូវពិនិត្យលើការបោះមែក( គូរោន )ក្នុងដើមនីមួយៗ បើសង្កេតឃើញថាដើមណាមានគូរោនមិនល្អគួរកាត់មែកខ្លះ ចោល រួមទាំងមែកងាប់ និង មែកដែលមានជំងឺ ។ ការកាត់នេះឱ្យនៅសល់ដងដើមតែមួយដើម្បីរក្សាគូរោនឱ្យបាន សមរម្យ និងងាយស្រួលថែរក្សាការកំចាត់សត្រូវស្វាយចន្ទី។ ពេលវាមានអាយុ ១-៣ឆ្នាំគួរកាត់មែកក្រោមឱ្យផុត ពីដីកម្ពស់៩០ស.ម។ សម្រាប់ដើមឱ្យផលហើយនៅពេលប្រមូលផលរួច ក៏គួរកាត់មែកចេញខ្លះដោយកាត់មែក នៅផ្នែកខាងក្នុងគូរោន។ ចុងរដូវភ្លៀង ឬមុនរដូវចេញផ្កាប្រមាណ ៣ខែ ត្រូវកាត់មែកខ្មែងចេញនៅពេលកាត់រួចហើយ និងមានរាងគូរោនសមរម្យហើយជៀសផុតពីជំងឺ និង សត្វល្អិតដោយងាយរក្សា និង ងាយប្រមូលផលហើយទទួលទិន្នផលបានច្រើនជាងមិនកាត់មែក ។

## ៩.៣. ការស្រោចស្រព:

ប្រសិនបើខ្វះទឹក ធ្វើឱ្យការលូតលាស់វា រអាក់រអួលយឺតជាងធម្មតា។ ដោយនៅឆ្នាំដំបូងគួរធ្វើ ការស្រោចទឹកនៅពេលគ្មានភ្លៀង ដើម្បីជួយបង្កើនសន្ទុះនៃការលូតលាស់ឱ្យបានធំរហ័ស និង ទទួលផលឆាប់ជាងប្រក្រតី។ បើនៅរដូវប្រាំងគួរយកស្មៅ និង ចំបើងទៅគ្របត្រង់គល់ដើម្បីរក្សាសំណើមឱ្យបានយូរ ។ នៅឆ្នាំបន្ទាប់ទៀតត្រូវធ្វើការស្រោចទឹកនៅរដូវក្តៅដែលមានរយៈពេលយូរៗតែប៉ុណោះ ការស្រោចទឹក ធ្វើឱ្យដើមលូតលាស់បានល្អហើយប្រការសំខាន់ គឺរក្សាសំណើមនៅក្នុងចន្លោះរងដាំដុះគឺត្រូវភ្ជួរតាមចន្លោះមុនពេលអស់ទឹកភ្លៀង។ ស្វាយចន្ទីអាចដុះលូតលាស់នៅតំបន់ដែមមានលក្ខខណ្ឌទឹកភ្លៀងតិចតួច។ទោះបីវាបន្ថែមប្រពន្ធ័ស្រោច ស្រពកំឡុងពេលរដូវក្តៅក៏ដោយ ជាពិសេសខែមករាដល់ខែមិនាត្រូវផ្តល់ទឹករយៈពេលពីរអាទិត្យម្តងៗ

២០០ ល/ដ ហើយផ្តល់ផលទ្វេរដង។ នេះជាលទ្ធផលស្រាវជ្រាវ មួយទទួលបានពីមជ្ឈមណ្ឌលស្រាវជ្រាវដំណាំស្វាយចន្ទីរបស់ឥណ្ឌា បរិមាណនៃការស្រោចស្រពមានការប្រែប្រួល ការផ្គត់ផ្គង់ទឹកដែលល្អគឺប្រើប្រាស់ការសម្រក់ទឹកក្នុងអត្រា ៦០-៨០ ល/ដ រយៈពេល ២ ថ្ងៃបន្ទាប់ពី ការចេញផ្កាដំបូងរហូតដល់ចេញផ្លែ និង ការវិវត្តន៍។

ស្វាយចន្ទីមិនអាចប្រឈម នឹងការលិចទឹកបានទេ នៅតំបន់ដែលមានភ្លៀងធ្លាក់ច្រើន គួរតែរៀបចំប្រពន្ធ័បង្ហូរទឹកចេញ។

## ៩.៤ ការអភិរក្ស ដី និងទឹក

នៅក្នុងករណីដីជំរាលចាំបាច់ជីករណ្តៅបណ្តោយ ២-២,៥ ម ទទឹង ០,៣ ម ជំរៅ ០,៤៥ ម ចម្ងាយ ២ ម ពីដើមនៅផ្នែកខាងលើទីជំរាល។ ករណីស្មើល្អត្រូវជីករណ្តៅរាងជារង្វង់ ឬ ជាការេ ចម្ងាយពីដើម ២ ម ជំរៅ ០,៣ ម និងមាត់រណ្តៅ ទំហំ ០,៣ ម គួរតែជីកដីជុំវិញដើម។ បន្ទាប់ពីការងារលើកដីជុំវិញដើមគួរតែប្រើប្រាស់គម្របសារធាតុ សរីរាង្គទប់ទល់នឹងការហូរច្រោះនៅរដូវវស្សា ហើយម៉្យាងទៀត ជៀសវាងការប៉ះពន្លឺដោយផ្ទាល់ នេះជាមធ្យោបាយ សម្រាប់ការពារសំណើមដីនៅរដូវក្តៅ។





ការជីករណ្តៅនៅជុំវិញគល់ដើម្បីកាត់បន្ថយការហូរច្រោះដីជាតិ

## ៩.៥ ការប្រើប្រាស់ជី

លាមកសត្វមានសារៈសំខាន់ណាស់ ចំពោះដំណាំស្វាយចន្ទីពេលនៅតូច ព្រោះវាធ្វើឱ្យកូនស្វាយចន្ទីលូតលាស់លឿន និងមានភាពរឹងមាំ ដោយវាជួយសម្រួលដល់ការលូតលាស់របស់ឫស។ ចំពោះស្វាយចន្ទីនៅតូចប្រើលាមកសត្វ ៦តោនក្នុងមួយហិកតាធ្វើឱ្យវាដុះលូតលាស់បានយ៉ាងលឿន។ ម្យ៉ាងវិញទៀត ពពួកសារធាតុសរីរាង្គដូចជាស្មៅដែលបានពីការសំអាតក្នុងចម្ការ កាកសំណល់ដំណាំផ្សេងៗ និងជាពិសេស ស្លឹករបស់ស្វាយចន្ទីដែលជ្រុះមក ជាប្រភពជីធម្មជាតិដ៏ល្អ សម្រាប់ផ្តល់ឱ្យស្វាយចន្ទី។

### ក. ជីកំប៉ុស្តិ៍

ដើមស្វាយចន្ទីដែល ពេញវ័យបានផលិតម៉ាស់ស្ងួត២០ គ.ក្រ ក្នុងមួយឆ្នាំ។ គួរដាក់បន្ថែមទៀតនូវជីកំប៉ុស្តិ៍ ៣៣ គ.ក្រ ឬ ៥០ គ.ក្រ នៃ FYM (កាកសំណល់នៅក្នុងកសិដ្ឋាន) មុនពេលខ្យល់មូសុងមកដល់។ ការដាក់ជីគួរដាក់ក្នុង កំរិត ១ ភាគនៃជីកំប៉ុស្តិ៍ ៣ ភាគស្លឹកឈើស្ងួតសម្រាប់រុក្ខជាតិនៅខ្ចី ហើយបន្ថែមបន្តិចម្តងៗ រហូតដល់រុក្ខជាតិ អាយុ ៥ឆ្នាំ។ ជីត្រូវដាក់ក្នុងរង្វង់សម្រាប់រុក្ខជាតិចាស់ហើយ គ្របគល់ដោយសារធាតុសរីរាង្គ។ ប្រសិនបើមានសំរាមស្ងួតគួរតែផ្តល់មិនបាច់ធ្វើការបែងចែកជាដំណាក់កាល។ ការបាញ់ទឹកនោម





ការប្រើប្រាស់ជីកំប៉ុស្តិ៍

គោ ១ លីត្រលាយ ទឹកធម្មតា ៦-១០ លីត្រ (១:១០ ពង្រាវ) ឬ ជីកំប៉ុស្តិ៍ទឹក ១ លីត្រ លាយទឹកធម្មតា ៤០ លីត្រ (១:៤០ពង្រាវ) បាញ់លើស្លឹកត្រួយខ្ចី និង កញ្ចុំផ្កាជួយសម្រួលដល់ការលូតលាស់បានល្អ ហើយក៏ទប់ទល់ជាមួយការវាយប្រហារពីជំងឺ និងកត្តាចង្រៃជាពិសេសសត្វមូសតែ។

## ខ. ជីគីមី

ដំណាំស្វាយចន្ទីត្រូវការជីទ្រាប់បាត ឬ ជីកំប៉ុស្តិ៍ពេលអាយុបាន៦ ខែ ដើម្បីជួយឱ្យមានការលូតលាស់ និងដើមរឹងមាំចំពោះជីគីមីក៏អាចប្រើបានដែរ ។ បរិមាណជីត្រូវដាក់ទៅតាមអាយុកាល និង ទិន្នផល បើអាយុច្រើនឬនៅពេលបានទិន្នផលខ្ពស់ត្រូវប្រើឱ្យបានច្រើន ដើម្បីបំពេញបន្ថែមនៅការខ្វះខាត ។

## គ. ការប្រើប្រាស់ជី

✔. នៅអាយុ១-៣ ឆ្នាំ គួរប្រើប្រភេទជី១២-២៤-១២ដាក់កំរិត២៥,១០០ ឬ ២០០ ក្រាម ក្នុងមួយដើម

✔. នៅអាយុ៤-៧ ឆ្នាំប្រើប្រភេទជី១៥-១៥-១៥ ដាក់កំរិត២០០-៣០០ ក្រាម ក្នុងមួយដើម

✔. នៅអាយុ៨ ឡើងប្រើប្រភេទជី១៣-១៣-២១ ដាក់កំរិត៣០០- ៥០០ ក្រាម ក្នុងមួយដើម

## ឃ. របៀបដាក់ជី

✔. ការដាក់ ត្រូវពិនិត្យចុងមែកបើវាដល់ត្រឹមណាយើងត្រូវធ្វើការដាក់ជីត្រឹមនោះហើយការដាក់ត្រូវដាក់ជុំវិញដើម ដោយភ្ជួរកប់ ។

✔. ការភ្ជួរ មិនត្រូវភ្ជួរឱ្យចូលជ្រៅទៅក្នុងរង្វង់ នៃកំពែងជីកជុំវិញស្ថិតនៅក្រោមមែក ដែលបោះចេញឡើយ ព្រោះអាចប៉ះពាល់ដល់ឫស ត្រូវបែងចែកជីជាបួនចំណែក ដោយ៣ ចំណែកដាក់ជុំវិញ កំពែងជីក និងមួយចំណែក

ទៀតដាក់ក្នុងដីទួលជុំវិញដើមតែមិនត្រូវដាក់ឱ្យជិតដល់គល់ឡើយព្រោះអាចធ្វើឱ្យសំបកដងដើមរលួយ និងអាចងាប់ដើម យើងត្រូវដាក់ជីនៅតាមរង្វង់នៃកំពែង ព្រោះចុងឫស ចាក់ចេញតាមខ្សែដេកបានប្រវែងកំពែងហើយឫសនេះជាប្រភេទឫសស្រូបយកជីជាតិ សម្រាប់ចិញ្ចឹមដងដើម ។

### ង. ពេលវេលាដាក់ជី

ការដាក់ជីត្រូវដាក់បីដងក្នុងមួយឆ្នាំ គឺ ៖

- ✓. លើកទី១ នៅដើមរដូវភ្លៀង
- ✓. លើកទី២ នៅចុងរដូវភ្លៀង
- ✓. លើកទី៣ នៅពេលកាន់ផ្លែ គឺចុងខែ មករា និង ខែ កុម្ភៈ ដោយពេលដាក់ជីរាល់លើកត្រូវធ្វើការស្រោចទឹក ដើម្បីឱ្យជីរលាយជ្រាបចូលក្នុងដីហើយឫសអាចស្រូបយកជីតាមរយៈការស្រូបយកទឹកទាន់ពេល ។

## ១០. ការគ្រប់គ្រងជំងឺ និងសត្វល្អិត

### ១០.១ ជំងឺ

#### ជំងឺរលួយគល់ និង ឫស

**លក្ខណៈបំផ្លាញ**

កើតឡើងនៅលើថ្នាលបណ្តុះកូនក្នុងថង់ឬថ្នាលបណ្តុះកូន។ លក្ខណៈនៃការបំផ្លាញគឺវាបំផ្លាញនៅបរិវេណគល់ និងឫសដំបូងឃើញឆ្អួតតាមគល់និងបន្ទាប់មកទៅជាពណ៌ត្នោតឬពណ៌ខ្មៅ បន្ទាប់ត្រួយ និងស្លឹកចាប់ផ្តើមស្រពោន និង ងាប់នៅពេលបន្ទាប់។ នៅបរិវេណគល់អាចឃើញសរសៃពណ៌ស និងនៅពេលដកដើមចេញឃើញ រលួយឫសនឹងមានពណ៌ខ្មៅ។ ជំងឺនេះអាចកើតនៅលើស្លឹក ដែលមានលក្ខណៈដូចរលាកទឹកក្តៅហើយទ្រនុងស្លឹកដែល នៅជាប់ស្នាមរលាកនោះមានពណ៌ខ្មៅ ជំងឺនេះរាតត្បាតនៅរដូវភ្លៀង ។

### វិធានការកំចាត់ និង ការពារ

ការការពារធ្វើឡើងដោយរៀបចំដីឱ្យរាបស្មើ ជ្រាបទឹកបានល្អហើយ ការដាក់គ្រាប់បណ្តុះមិនឱ្យជ្រៅពេកទេ ការដាក់ជីអាសូតត្រូវបន្ថយខ្លះ ឬ ហាលដីឱ្យបានល្អ ឬធ្វើ Fumigation (បង្ហុយសារធាតុថ្នាំគីមីដើម្បីសម្លាប់ពពួកមេរោគបង្កជំងឺ) ដីជាមួយមេទីលប្រូម៉ាយ ក្នុងអត្រា ០,៥ គ.ក្រ ក្នុងដី ១ ម៣ ។

### ជំងឺរលួយផ្លែ

### លក្ខណៈបំផ្លាញ

កើតឡើងពីផ្សិតមួយប្រភេទដែលរាតត្បាតនៅពេលចេញផ្លែ នៅក្នុងខែមិនា ដល់ ខែកក្កដានៅពេល ដែលផ្លែចាប់ផ្តើមទុំ។ ផ្លែ វាមានលក្ខណៈពណ៌ខ្មៅហើយរីកធំពេញផ្លែទាំងមូល ជួនកាលគេសង្កេតឃើញមានផ្សិត ឬ បាក់តេរីប្រភេទផ្សេងៗចូលរួមបំផ្លាញដែលធ្វើឱ្យរលួយមានសណ្ឋានជាពពុះជួនកាលវាក៏កើតនៅលើផ្លែខ្ចីផងដែរ។ តែជួនកាលវាបំផ្លាញទៅលើគ្រាប់ និង កញ្ចុំផ្កាដែលធឱ្យរលួយមានពណ៌ខ្មៅ បន្ទាប់មកក៏ធ្វើឱ្យផ្ការុះរោយ។

### វិធានការកំចាត់ និង ការពារ

✓.ការកំចាត់ដោយប្រើថ្នាំ គូប្រាវីត (Cupravit) ក្នុងអត្រា ៥០-៦០ ក្រាម ក្នុងទឹក ២០ លីត្រ។

✓.ថ្នាំគូប្រាវីត (Cupravit) ជាថ្នាំសំលាប់ពពួកផ្សិតដែលបង្កភាពចង្រៃលើដំណាំ។

### ជំងឺចំណុចនៅលើស្លឹក ឬ ខ្លោចស្លឹក( Pestalotia sp. )

### លក្ខណៈបំផ្លាញ

វាកើតឡើងដោយសារផ្សិតច្រើនប្រភេទ ដែលសង្កេតឃើញនៅលើ

ដើមស្វាយចន្ទីមានអាយុមិន លើស ២ឆ្នាំ។ ភ្នាក់ងារបង្កគឺផ្សិតឈ្មោះ ប៉េស្តាឡូទីយ៉ា អេសប៉េ ធ្វើឱ្យស្លឹកកើតមានចំណុចពណ៌ប្រផេះហើយព័ទ្ធដោយពណ៌ត្នោតក្រហមដែលមានទំហំ ០,២-២ ស.ម ហើយតែងកើតនៅលើស្លឹកចាស់។ ជាពិសេសវត្តមានរបស់វាច្រើន កើតឡើងចាប់ពី ខែកញ្ញា ដល់ ធ្នូ។ យើងអាចប្រើល្បាយ ប័រដូ(Bordeaux) លាយហើយ កំហាប់ ១%. ឧបផ័រអុកស៊ីក្លរីដ ០,៣០% ឬ បែនឡែត ០,៣០%។

ផ្សិតមួយប្រភេទទៀតឈ្មោះ កូឡិចទ្រីជុម អេសប៉េ កើតនៅលើស្លឹកខ្ចី និង ផ្សិតឈ្មោះ សេកូស្ពោរ៉ា អេសប៉េ ធ្វើឱ្យស្លឹកមានចំណុចជ្រុងៗពណ៌ត្នោតមានទំហំ ០,១-០,៤ ស.ម បើសិនមានការរាតត្បាតខ្លាំងធ្វើឱ្យស្លឹក និង មែកស្ងួតហើយបែក ។




*រោគសញ្ញាជំងឺអុជស្លឹកលើស្លឹកស្វាយចន្ទី*

## វិធានការកំចាត់ និង ការពារ

✓. ស្លឹកដែលជ្រុះ ត្រូវប្រមូលហើយដុតចោលនៅខាងក្រៅ ចម្ការ ។

✓. ផ្តល់ជី នៅជុំវិញដើមនៅដើម រដូវក្តៅ ។

✓. ការពារនូវសំណើមចម្ការ ទាំងរុក្ខជាតិដែលត្រូវការពារ និង ដំណាំដែលដុះចេញដោយឯកឯង។

✓. ការកំចាត់ត្រូវបាញ់ថ្នាំ ដែលមានសារធាតុទង់ដែង ជាមួយនឹងម្នាងសិលាបាញ់លើស្លឹកក្រោយរដូវភ្លៀង ឬ ប្រើគូប្រាវីត (ថ្នាំសម្លាប់ផ្សិត) អត្រា ៥០-៦០ ក្រាម លាយទឹក ២០ លីត្រ បាញ់ម្តងម្កាល ។

### ជំងឺក្រៀមកញ្ចុំផ្កា

កើតឡើងដោយសារផ្សិតមួយប្រភេទ ដែលធ្វើឱ្យកញ្ចុំផ្កាស្ងួតមានពណ៌ត្នោតចាស់ផ្កានឹងរុះរោយ បើសិនកាន់ផ្លែក៏ត្រូវជ្រុះមុនកំណត់ដែរ។ ផ្សិតប្រភេទនេះផ្តើមបំផ្លាញទៅលើទងកញ្ចុំផ្កាអាការៈនេះកើតឡើងក្រោយពេលដែលមានការបំផ្លាញដោយសារមមាចភ្លើងនឹងជាភ្នាក់ងារចម្លងផ្សិតបន្ថែមទៀតផង។




ជំងឺក្រៀមកញ្ចុំផ្កា

## វិធានការការពារ និងកំចាត់

✓. ត្រូវបាញ់ថ្នាំការពារពពួកមមាច ដែលជាប្រភេទចម្លងតែបើឃើញ

មានការបំផ្លាញរួចទៅហើយត្រូវប្រើថ្នាំបេនឡេត ៥០ភាគរយក្នុងអត្រា ៥-១២ ក្រាម ជាមួយទឹក ២០ លីត្រ ។

## ១០.២ សត្វល្អិតលើដំណាំស្វាយចន្ទី

តាមការសិក្សាស្រាវជ្រាវ មានសត្វល្អិតប្រមាណជា ៦០ប្រភេទ បំផ្លាញលើដំណាំស្វាយចន្ទី។ សត្វល្អិត បំផ្លាញសំខាន់ៗ មានដូចជាដង្កូវដួង មូសតែ ដង្កូវស៊ីញ៉ៅ ដង្កូវព័ទ្ធស្លឹក និងផ្កា ដង្កូវចោះផ្លែ និងគ្រាប់។

### ក. ដង្កូវដួង

ដង្កូវដួង ជាសត្វដែលស៊ីរូងជាលិកាខាងក្នុង ហើយលាក់ខ្លួននៅក្នុងដើមស្វាយចន្ទី។ ពេលពេញវ័យ ស្ថិតក្នុងពពួកសត្វល្អិតស្លាបរឹង មានរាងទ្រវែង ពណ៌ក្រហមត្នោត ទំហំមធ្យម។ ក្បាល និងទ្រូង មានពណ៌ត្នោតចាស់ ឬខ្មៅសុទ្ធ ហើយមានវគ្គមានស្មើរពេញមួយឆ្នាំ។ យើងអាចសម្គាល់ពីការបំផ្លាញរបស់ដង្កូវដួងបាន តាមរយៈឃើញមានរន្ធតូចៗ ព្រមទាំងមានចេញជ័រ និងកំទេចឈើល្អិតៗតាមរន្ធនោះ នៅកន្លែងបំផ្លាញក្បែរៗគល់ស្វាយចន្ទី។ ហើយនៅដំណាក់កាលបន្ទាប់ ស្លឹកប្រែជាពណ៌លឿង ហើយចាប់ផ្តើមជ្រុះដោយសារជាលិកាដឹកនាំត្រូវបានបំផ្លាញ និង ទីបំផុតមែកតូចៗ ត្រូវងាប់ ហើយរុក្ខជាតិទាំងមូលចាប់ផ្តើមងាប់បន្តិចម្តងៗ។



ដង្កូវដួងពេលជាដង្កូវ



មេចំណាស់ដង្កូវដួងចន្ទី

### វិធានការការពារ និងកំចាត់

✓. យកលួសទន់ចាក់ចូលទៅក្នុងរន្ធដឹកឌឿ ត្រូវរុកចូលឱ្យជ្រៅរហូតដល់ឮសម្លេង ឬចេញទឹកសៗ ដូចពពុះ ហៀរចេញ បង្ហាញថាបានកំចាត់កូនដង្កូវ ឬដឹកឌឿក្នុងរន្ធនោះហើយ។

✓. ផ្នែកសំបកដែលយើងឈូសចេញ ត្រូវលាបនឹងទឹកល្បាយប៊័រដូ ១០ ភាគរយ។

✓. អាចយកប្រេងម៉ាស៊ីនចាស់ៗ លាបលើដើម ពីដីឡើងលើកម្ពស់ ១ម ក្នុងខែកញ្ញា វិច្ឆិកា និងមករា ការពារការញាស់ពងរបស់ដង្កូវដួង។

### ខ. មូសតែ

មូសតែ ជាសត្វដែលគេចាត់ទុកថា បំផ្លាញធ្ងន់ធ្ងរបំផុតលើដំណាំស្វាយចន្ទី ហើយធ្វើឱ្យប៉ះពាល់ដល់លក្ខណៈសេដ្ឋកិច្ចលើដំណាំ ជាងសត្វណាៗទាំងអស់។ មូសតែចុចជញ្ជក់យករុក្ខរសពីត្រួយខ្ចី ចង្កោមផ្កា គ្រាប់ និងផ្លែខ្ចី ដោយបង្ហាញជាស្នាមជាំខ្មៅ នៅកន្លែងរងការបំផ្លាញ។ សត្វពេញវ័យចេញរកស៊ីនៅពេលព្រឹកព្រលឹម អំឡុងពេលម៉ោង ៦ ទៅម៉ោង ១០ព្រឹក ហើយធ្វើការបំផ្លាញដោយបន្សល់ទុកស្នាមប្រហែល ១៥០ក្នុងមួយថ្ងៃ។



មូសតែបៃតងពេញវ័យ



មូសតែក្រហមពេញវ័យ

### វិធានការកំចាត់ និងការពារ

✔. ជំរុញឱ្យមានសត្វមានប្រយោជន៍ ជាពិសេស សត្វអង្រ្កង ដើម្បីធ្វើការកំចាត់មូសតែ។

✔. ដុតសំរាមបង្ហុយនៅលើខ្យល់ ដើម្បីដេញមូសតែ នៅក្នុងរដូវដែលវាបំផ្លាញ។

✔. ប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិត គីណាល់ហ្វូស (255 EC) 0.05%, កាបារីល (50% WP) 0.01% , ហ្វូស្វាមីដុង (85% WSC) 0.03%។

### គ. ដង្កូវស៊ីញ៉ែ

ដង្កូវស៊ីញ៉ែ ជាសត្វបំផ្លាញខ្លាំងលើដំណាំស្វាយចន្ទី ជាធម្មតាគេសង្កេតឃើញមានក្រោយរដូវភ្លៀងអំឡុងពេលលូតលាស់ស្លឹកថ្មី។ រុក្ខជាតិក្មេងទទួលរងការបំផ្លាញ ច្រើនជាងរុក្ខជាតិចាស់។ យើងតែងឃើញដង្កូវតូចៗទើបញាស់ចាប់ផ្តើមរូងស្រទាប់អេពីឌឺមីសនៃផ្ទៃខាងលើ របស់ស្លឹកខ្ចី។ បន្ទាប់មកស្រទាប់ស្តើងនៅកន្លែងរងការបំផ្លាញនោះប៉ោង មានពណ៌សរាងប្រផេះ។ នៅពេលស្លឹករងការបំផ្លាញធ្វើឱ្យស្លឹកឆាប់ចាស់ ពិសេស នៅត្រង់ចំណុចរងការបំផ្លាញនោះបង្កើតបានជារន្ធដ៏ធំដែលបណ្តាលឱ្យស្លឹកងាប់ ឬស្រពោនមុនអាយុ។





ដង្កូវស៊ីញ៉ែ និងការបំផ្លាញ

### វិធានការកំចាត់ និងការពារ

✔. វិធានការមេកានិចៈ ប្រមូលស្លឹកដែលរងការបំផ្លាញ កំទេចចោល។

✔. វិធានការជីវសាស្ត្រៈ ប្រើប៉ារ៉ាស៊ីតដូចជា Chelonus sp, Sympiesis sp ដើម្បីកំចាត់ដង្កូវ។

✔. វិធានការគីមីៈ អំឡុងខែតុលា ដល់វិច្ឆិកា បាញ់ថ្នាំ monocrotophos កំរិត ០,០៥% ( ១,៥ ម.ល/ល ) ឬ parathion កំរិត ០,០២៥% នៅពេលចេញត្រួយ អាចការពារការបំផ្លាញរបស់ដង្កូវស៊ីញ៉ៀនេះ។ គេបាញ់ Phospho -midon កំរិត ០,០៥% ឬ Fenitrothion កំរិត ០,០៥% កំរិត ០,០៧% នៅពេលដើមទើបចេញត្រួយ។

### ឃ. ដង្កូវព័ទ្ធត្រួយ និងស្លឹក

ដង្កូវចាប់ផ្តើមមូរស្លឹក និងពន្លកត្រួយ នៅផ្នែកខាងចុងជាកញ្ចុំ។ សំណាញ់ដែលព័ទ្ធស្លឹកជាកញ្ចុំជាជម្រក សម្រាប់ដង្កូវជាច្រើន នៅដំណាក់កាលចាំបាច់។ ដង្កូវរស់នៅជាក្រុម ហើយពួកវាចិញ្ចឹមជីវិតដោយកកេរផ្ទៃស្លឹក និងនៅដំណាក់កាលចុងក្រោយ នៃដង្កូវពួកវាស៊ីស្លឹកឡើងប្រហោងអស់ បន្សល់ទុកតែទ្រនុងកណ្តាល។ ការស៊ីស្លឹកនេះ បណ្តាលឱ្យស្លឹកដែលពួកវាព័ទ្ធសំបុកនោះ ក្លាយជា



ដង្កូវព័ទ្ធត្រួយ និងស្លឹក



ការបំផ្លាញរបស់ដង្កូវព័ទ្ធត្រួយ និងស្លឹក

ស្ងួត និងមានពណ៌ខ្មៅ។ ពេលទទួលរងការបំផ្លាញខ្លាំង ធ្វើឱ្យពន្លកត្រួយងាប់ និងរាំងស្ទះដល់ការធ្វើរស្មីសំយោគ។

### វិធានការកំចាត់ និងការពារ

✓. វិធានការមេកានិចៈ ដើមនៅក្នុងចម្ការ គួរតែដើរត្រួតពិនិត្យរៀងរាល់មួយខែម្តង នៅតាមកញ្ចុំមែក និង ស្លឹក។ ចំពោះកញ្ចុំណាដែលមានការបំផ្លាញ ឬមានដង្កូវ គួរតែបំផ្លាញចោល និងធ្វើការតាក់តែង ដើម្បីឱ្យ គ្រប់មែកនៃដើមទទួលពន្លឺបានគ្រប់គ្រាន់ ដែលអាចកាត់បន្ថយការបំផ្លាញពីដង្កូវព័ទ្ធត្រួយ និងស្លឹក។ ចំពោះស្លឹកដែលរងការបំផ្លាញធ្លាក់មកលើដី ក៏ត្រូវប្រមូលយកមកបំផ្លាញចោលដែរ ព្រោះវាអាចមាន វត្តមានដង្កូវ ឬដឹកឌឿ។ ចំពោះដីនៅក្រោមដើម គួរតែភ្ជួរដើម្បីសម្លាប់ដង្កូវ នៅរដូវត្រជាក់។

✓. វិធានការជីវសាស្ត្រៈ គេប្រើប្រេដាទ័រ (Parena laticincta, Oecama sp) អាចស៊ីពួកវានៅដំណាក់កាល ដង្កូវ និងប៉ារ៉ាស៊ីត (Hormius sp, Tetrastichus israeli, Trichogramma chilonis) អាចធ្វើ ប៉ារ៉ាស៊ីត ទៅលើដង្កូវ និងដឹកឌឿបាន។

✓. វិធានការគីមីៈ បាញ់ថ្នាំ Endosulfan 0,0៥% ពេលចេញត្រួយ។

## ១១. ការប្រមូលផល និងការទុកដាក់

ស្វាយចន្ទីគួរប្រមូលផលដោយការរើសគ្រាប់ ដែលទុំជ្រុះពីដើមស្វាយចន្ទី ជៀសវាងការបេះដែលធ្វើឱ្យប៉ះពាល់ដល់ផ្កា និងផ្លែដែលនៅខ្ចីមិនទាន់ទុំ។ គ្រាប់ប្រលេះចេញពីសាច់រួច ត្រូវលាងជាមួយទឹកឱ្យស្អាត និងហាលថ្ងៃពី ២-៣ ថ្ងៃ ទាល់តែស្ងួត។ បន្ទាប់មក ច្រកទុកក្នុងបាវ ឬការ៉ុងដោយទុកឱ្យផុតពីដីយកល្អគ្រាប់ស្វាយចន្ទី គួរលក់នៅឆ្នាំ ដែលប្រមូលផលឱ្យអស់។

ជាប្រក្រតីស្វាយចន្ទីនឹងផ្តើមឱ្យផលគ្រាដំបូងពេលអាយុ២-៣ ឆ្នាំ ដោយ

 

ផ្លែស្វាយចន្ទីនៅពេលធ្វើការប្រមូលផល

ផ្តើមចេញផ្កាតាំងពីខែធ្នូ រហូតដល់ ខែកុម្ភៈ អាស្រ័យទៅតាមពូជស្រាល កណ្តាល និងធ្ងន់ គឺអាចប្រមូលផលនៅក្នុងខែកុម្ភៈដល់ខែឧសភា។ នៅក្នុងដើម មានផ្លែទុំមិនបានស្រុះគ្នាទេ ជាមធ្យមគឺប្រមូលផលយ៉ាងតិច ៤ ដង ដែលធ្វើឡើងតាមរយៈពេលមួយសប្តាហ៍ ម្តង។ ការប្រមូលផល គួរប្រមូលផលយកផ្លែទុំ និងផ្លែដែលធ្លាក់នៅលើដី បើប្រមូលផលផ្លែដែលមិនទាន់ទុំល្អ គ្រាប់ ដែលបានមកត្រូវស្វិតតូច គុណភាពទាប មិនអាចប្រើជាគ្រាប់ពូជបាន។

ការប្រមូលផលត្រូវប្រើកន្ត្រក ឬ ជាល ជៀសវាងធ្វើឱ្យផ្លែជាំសម្រាប់ការលក់ដូរនៅក្នុងស្រុកទាំងផ្លែ ទាំងគ្រាប់ តែបើចង់បានគ្រាប់ដែលមានគុណភាពល្អសម្រាប់ការនាំចេញ គួរទុកផ្លែឱ្យជ្រុះឯកឯងប៉ុន្តែត្រូវប្រញាប់ ប្រឡេះគ្រាប់ចេញឱ្យទាន់ពេល ព្រោះអាចធ្វើឱ្យគ្រាប់ឆ្លងជំងឺស្វិតពីផ្លែ។ បន្ទាប់មកត្រូវយកទៅហាលថ្ងៃយ៉ាងតិច ៣-៥ ថ្ងៃ ដើម្បីបន្ថយសំណើមនៅក្នុងគ្រាប់ដោយរក្សាសំណើមមិនឱ្យលើសពី ១២ ភាគរយ ដើម្បីរក្សាទុកឱ្យបានយូរដោយ មិនរលួយចោល។ បន្ទាប់មកត្រូវបែងចែកគ្រាប់លិចទឹក និងគ្រាប់អណ្តែតទឹក ឬគ្រាប់តូចដាក់ដោយឡែក។

ការឱ្យផលក្នុងរយៈពេលកំពុងលូតលាស់ស្វាយមានអាយុតិចនៅឡើយ

មានកម្រិតតិចតែវានឹងកើនឡើងជា បន្តបន្ទាប់រហូតដល់មានអាយុ ១០ ឆ្នាំ។ ស្វាយចន្ទីឱ្យផលឡើងចុះអាស្រ័យទៅតាម ដី ការថែទាំ និងការអំណោយផលនៃអាកាសធាតុ។ នៅលើដីដែលមានជីជាតិជ្រាបទឹកល្អ និង មានការថែទាំបានត្រឹមត្រូវ ដើមស្វាយចន្ទីអាចនឹង មានអាយុ ៧០-១០០ ឆ្នាំ តែទិន្នផលជាអតិបរិមា មិនលើសពី២៥ ឆ្នាំឡើយ។ ជាមធ្យម ៣-៥ ឆ្នាំឱ្យទិន្នផល ប្រមាណ ១-៣ គ.ក្រ ក្នុងមួយដើម អាយុពី ៦-១០ ឆ្នាំឱ្យទិន្នផលជាមធ្យម ៥-២០ គ.ក្រ ក្នុងមួយដើម និង អាយុ ១០ឡើងទៅ ឱ្យទិន្នផលជា មធ្យម ១០-៦០ គ.ក្រក្នុងមួយដើម។៚

ម.ព.ឯ.ក AIDOC
Code:
Date:
Donated by:

## ឯកសារយោង៖

១. ឃួន អៀង និងស៊ីប បញ្ញាសូទ្បី (២០០៦)ការគ្រប់គ្រងចម្ការស្វាយចន្ទី

២. សុខ វណ្ណនី ១៩៩៦ , ផលិតកម្មដំណាំស្វាយចន្ទីរបស់ក្រុមហ៊ុនអាក្រូស្តារនៅស្រុកជើងព្រៃខេត្តកំពង់ចាម

៣. ប៉ែន វិចិត្រ ២០០៣ , ដំណាំស្វាយចន្ទីជាលក្ខណៈគ្រួសារនៅស្រុកមេមត់ ខេត្តកំពង់ចាម

៤. CAB International ( 2006 ). Crop Protection Compendium

៥. Ikisan ( 2000 ). Cashew Insect Management, www.ikisan.com/links/tn_cashewInsectManagement.shtml

៦. R.C Mandal ( 2000 ).Cashew Production and Processing Technology

៧. Varanashi, K &Yadukumar N. & Shankar Raj N.S ( 2007 ). Hand Book on Organic Cashew Cultivation. India





**អាសយដ្ឋាន** : ផ្ទះលេខ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់
ខណ្ឌចម្ការមន រាជធានីភ្នំពេញ

**ទូរស័ព្ទលេខ** : (០២៣) ២១៥ ៨១៩/០១២ ៨៣ ៧៩ ៤៥

**ទូរសារលេខ** : (៨៥៥)២៣ ២១០ ៩៤៨

**Facebook** : នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម - **Department of Agricultural Extension**

**គេហទំព័រ** : **http://www.maff.gov.kh**